

# លេងក្រដាស

Mala Kumar

Ruchi Shah

letsreadasia.org



ខ្យល់បក់មក ប៉ើងក្រដាសមួយសន្លឹក
ចូលមកក្នុង។ អាជូ ក៏រើសវាឡើង
ហើយអង្គុយចុះគូររូបព្រះអាទិត្យ។
”អូ! រូបនេះអាក្រក់មើលណាស់!” ថា
រួច នាង ក៏ញីក្រដាសហើយបោះវា
ចេញទៅក្រៅបង្អួច។ ក្រដាសក៏ជ្រុះ
ចំក្បាល ស៊ីម។ ស៊ីម ពោលដោយ
ត្រេកអរ៖ ”អ្ហា! នេះជាបាល់ទេតើ!”



ស៊ីម បោះបាល់ក្រដាសទៅលើ ហើយមើលវាធ្លាក់មកវិញ។ គេបោះកាន់តែខ្ពស់ វាធ្លាក់ចុះកាន់តែលឿន។ ស៊ីម ក៏គប់បាល់ក្រដាសតម្រង់ទៅ ស៊ីដា ជាប្អូនស្រីរបស់គេ។ ”គប់ឯងចំហើយ!” ស៊ីម ស្រែកដោយរីករាយ។



ស៊ីដា ក៏រើសដុំក្រដាសនោះឡើង។
បន្ទាប់មក នាងដោតខ្មៅដៃចូល ហើយ
និយាយថា៖ ”ចង់ញ៉ាំស្ករគ្រាប់នេះ
ទេ? ពេលធំឡើង ខ្ញុំនឹងបើកហាងលក់
ស្ករគ្រាប់ទាំងនេះ។”



បន្ទាប់មក ពិទូ ក៏មកដល់ ហើយ
សួរ៖ ” តើខ្ញុំសុំស្ករគ្រាប់នេះបានទេ?
”បន្ទាប់មកគេក៏ធ្វើជាញ៉ាំស្ករគ្រាប់នោះ
ហើយមូរដុំក្រដាសនោះចុះឡើង។ ពិទូ
ស្រែកឡើង៖ ”អាឡូ អាឡូ អាឡូ មួយ
ពីរ បី!! ឥឡូវនេះ ខ្ញុំនឹងច្រៀងចម្រៀង
ឲ្យស្តាប់មួយបទ។”



ពិទូ ច្រៀងចប់យ៉ាងពីរោះ។ អាជូ ក៏ទាញយកដុំក្រដាសពីដៃពិទូ។ នាងលាតក្រដាសនោះឲ្យស្មើ ហើយបត់ធ្វើជាទូក។



”ពិទូ អ្នកចម្រៀងដ៏ល្បី នឹងធ្វើដំណើរ
តាមទូកនេះទៅជុំវិញពិភពលោក
ហើយ!” ស៊ីម ស្រែកសុំថា៖ ”ឲ្យខ្ញុំសុំ
ទៅផងបានទេ?”



ស៊ីម រើសទូកនេះឡើង ហើយលាតវាឲ្យស្មើដោយយកចិត្តទុកដាក់។ បន្ទាប់មកគេក៏បត់វាដូចកូនកន្សែងដៃ។ រួច ស៊ីមក៏កាត់ជ្រុងវាចេញ ហើយលាក្រដាសវិញ។



”ទាំងអស់គ្នា មើលមកនេះ! ញញឹមមួយ!” ស៊ីមនិយាយបណ្ដើរ កាន់ក្រដាសដែលមានប្រហោងចំកណ្ដាលបណ្ដើរ។ ស៊ីដា ពិទូ និង អាជូ ញញឹមធ្វើមុខស្ញេញ ហើយក៏នាំគ្នាសើចកក្អឹក។ រួច ស៊ីម ក៏ញីកាមេរ៉ាក្រដាសរបស់ខ្លួន។



បន្តិចក្រោយមក ណាល់ ក៏បណ្ដើរសត្វលាមកដល់។ ណាល់ រើសខ្មៅដៃរបស់ អាជូ មកគូសជុំវិញប្រហោងក្រដាសនោះ។ អាជូ ក៏លាន់មាត់ថា៖ ”ព្រះអាទិត្យអីក៏ស្អាតម្ល៉េះ! ខ្ញុំមិនដែលឃើញទេ!”



រំពេចនោះ លារបស់ ណាល់ ក៏ឆក់
យកក្រដាសរូបព្រះអាទិត្យពីដៃ អាជូ
មកទំពាយ៉ាងលឿន។ វា ភើយ៉ាងឮ។
បន្ទាប់មក ទឹកមុខសត្វលា ក៏ប្រែជា
ចម្លែក។ ពេលនេះមានអ្នកណាអាច
ប្រាប់បានទេថា តើមកពីវាខំស៊ីលឿន
ពេកដោយមិនបានទំពា ឬក៏មកពីវាស៊ី
ព្រះអាទិត្យ?



Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Paper Play, author: Mala Kumar. illustrator: by Ruchi Shah. Published by Pratham Books, https://storyweaver.org.in/stories/156-paper-play © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Udom Kroch and Chou Chinith